ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានតំណាងកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលការិនីខ្មែរ៨នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៨នាក់** ដូចខាងក្រោមៈ

(១) ពលការិនី **ស.ច** អាយុ៣៥ឆ្នាំ មកពីស្រុកស្នួល ខេត្តក្រចេះ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត កាលពីខែមករា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូត នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីស្នើសុំកិច្ចអន្តរាគមន៍។ ក្រោមការសម្របសម្រួលរបស់ស្ថានទូត និយោជករបស់ពលការិនី បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ និងលិខិតឆ្លងដែនជូននាងវិញ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧។

(២) ពលការិនី **ម.ស** អាយុ២២ឆ្នាំ មកពីស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បានទៅម៉ាឡេស៊ីធ្វើការងារតាមផ្ទះ កាលពីខែមករា ឆ្នាំ២០១៥ តាមរយៈមេខ្យល់នៅកម្ពុជា។ ដោយសារមានជម្លោះជាមួយនិយោជក នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៧ និយោជកបានប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ជូនពលការិនី និងបានជូននាងទៅដល់ស្ថានទូត។ ពលការិនី បានស្នើសុំស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលការិនីទាំង២នាក់ខាងលើ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៣ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **០៧:៣៥** នាទីព្រឹក តាមជើងយន្តហោះ AK 536 ។

(៣) ពលការិនី **ង.ច.ថ** អាយុ២៨ឆ្នាំ មកពីស្រុកអង្គរជ័យ ខេត្តកំពត

(៤) ពលការិនី **ជ.ជ.រ** អាយុ២៩ឆ្នាំ មកពីស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

(៥) ពលការិនី **ញ.រ** អាយុ៣៦ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

ពលការិនី **ង.ច.ថ** និង **ជ.ជ.រ** បានទៅម៉ាឡេស៊ី កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ចំណែកពលការិនី **ញ.រ** បានទៅម៉ាឡេស៊ី នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦។ ពលការិនីទាំង៣នាក់ បានទៅធ្វើការជាអ្នកបោសសំអាត តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក ពួកគេបានទៅស្ថានទូតនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជកបានយល់ព្រមប្រគល់លិខិតឆ្លងដែនជូនពលការិនីទាំង៣នាក់វិញ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលការិនីទាំង៣នាក់ខាងលើ បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៩ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

**(៦)** ពលការិនី **អ.រ.ណ** អាយុ៣២ឆ្នាំ មកពីស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ីធ្វើការងារតាមផ្ទះ កាលពីខែមករា ឆ្នាំ២០១៦ តាមរយៈមេខ្យល់នៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូតនៅខែមករា ឆ្នាំ២០១៧ ស្នើសុំទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានយល់ព្រមប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ជូននាង នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧។

**(៧)** ពលការិនី **ម.ល** និង **(៨)** ពលការិនី **ស.ល.ជ** ដែលអ្នកទាំងពីរមានអាយុ២០ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំដូចគ្នា បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ តាមរយៈមេខ្យល់នៅកម្ពុជា។ ដោយធ្វើការលំបាក ពលការិនីទាំងពីរ បានទៅស្ថានទូតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ស្នើសុំជួយទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនីទាំងពីរ បានយល់ព្រមប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ជូនពួកគេ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ ។

ពលការិនីទាំង៣នាក់ចុងក្រោយ បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៨ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **១០:០០**នាទីព្រឹក តាមជើងយន្តហោះ MH754 ៕

ភ្នំពេញ, ថ្ងៃទី១២ ខែ មេសា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ